ព្រឹត្តិបត្រអង្គការស្ត្រីខ្មែរកម្ពុជាក្រោម

Khmer Kampuchea Krom Women Organization Bulletin

ចេញផ្សាយប្រចាំអង្គមាស ឆ្នាំទី២ លេខ១៤ ពីថ្ងៃទី១៦.២៨ ខែកុម្ភៈ ឆ្នាំ២០០៤

អង្គការ-សមាគមខ្មែរកម្ពុជាក្រោម ធ្វើបុណ្យគម្រប់ខួប២ឆ្នាំប្រគេនព្រះគេងគុណ ហ៊ាង សុខធឿន

កាលពីថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០០៤ អង្គការ-សមាគមខ្មែរកម្ពុជាក្រោម បានធ្វើបុណ្យគម្រប់ខួប០២ឆ្នាំប្រគេនព្រះវិញ្ញាណក្ខន្ធ ព្រះគេងគុណ **ហ៊ាង- សុខធឿន** ដែលបានសុគតកាលពី២ឆ្នាំមុនៅវត្តទ្រង់ជ្រឹង ឃុំបឹងធំ ស្រុកអង្គស្នួល ខេត្តកណ្តាល ក្រោមអធិបតីភាព **ឯកឧត្តម យន្ត ៥រ៉ូ** ប្រធានមជ្ឈមណ្ឌលវប្បធម៌ខ្មែរកម្ពុជាក្រោម និងជាសាសនិកជ្ញាសភាជាតិ ព្រមទាំងមានការចូលរួមយ៉ាងច្រើនកុះករពីសំណាក់ព្រះសង្ឆ និងបេក្ខជនជាសមាជិកខ្មែរកម្ពុជាក្រោម។ បន្ទាប់ពីឈរស្ងឹងស្ងាត់ពេលព្រះវិញ្ញាណក្ខន្ធព្រះគេងគុណ **ហ៊ាង សុខធឿន** រួចមក **ឯកឧត្តម យន្ត ៥រ៉ូ** បានថ្លែងថា បន្ទាប់ពីព្រះអង្គបានចូលរួមធ្វើបាតកម្មនៅបុនស្ពានទុតវៀតណាមមកនេះ ព្រះអង្គបានណាត់ជួបនៅវត្តទ្រង់ជ្រឹងវិញ។ លុះប្រឹកឡើងស្រាប់តែទទួលដំណឹងមានថាព្រះអង្គបានសុគត ហើយយកទៅបញ្ជូនយ៉ាងឆាប់ក្រហាយទៀតផង ទើបធ្វើឱ្យមានការភ្ញាក់ផ្អើលនិងមានមន្ទិលសង្ស័យយ៉ាងខ្លាំងចំពោះការណីសុគតនោះ ហើយអាជ្ញាធរមូលដ្ឋាន និងសមត្ថកិច្ចខេត្តក៏ស្ទាត់ណមិនបានអនុញ្ញាតឲ្យក្រុមគ្រួសារព្រះអង្គ ពិសេសអង្គការ-សមាគមខ្មែរកម្ពុជាក្រោមចូលរួមស៊ើបអង្កេតក្នុងការណីមោតមសម្លាប់អង្គការសង្ឆមស៊ីវិលសំទ្ធលរៀបចំបុណ្យនៅវត្តទ្រង់ជ្រឹងក៏ត្រូវបានហាមឃាត់ដែរ។ ដូច្នេះការសុគតរបស់ព្រះគេងគុណ **ហ៊ាង សុខធឿន** ពិតជារឿងមួយដែលមានអាថិកំបាំងយ៉ាងពិតប្រាកដ ហើយឯកឧត្តមសូមអំពាវនាវដល់អាជ្ញាធរឱ្យមានការស៊ើបអង្កេតបន្ត។

អាសយដ្ឋាន: ផ្ទះលេខ១៤ ផ្លូវ២៤៤ ក្រុម១៨ សង្កាត់បឹងកេងកង១ ខណ្ឌចំការមន ភ្នំពេញ

ទូរស័ព្ទ: ០១១ ៨១ ២៣ ២៥ / ០៩៤ ៩៣ ៥៥ ៥៣

E-mail: kkkwo@yahoo.com

ចែកចាយនោយឥតគិតថ្លៃ

ព្រឹត្តិបត្រទី០១

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ផ្នែកសារ

សេចក្តីថ្លែងការណ៍

ក្នុងឋានៈជាអ្នកតំណាងរាស្ត្រ នៃលក្ខខណ្ឌមានកំណើតជាខ្មែរកម្ពុជាក្រោម ខ្ញុំមានការណែនាំយ៉ាងខ្លាំងចំពោះទង្វើរំលោភច្បាប់របស់មន្ត្រីនគរបាលខេត្តស្វាយរៀង និងមន្ត្រីនគរបាលវៀតណាម មកលើលោក ហ្ស៊ី សុធី ជាបុគ្គលិកមិត្តសមាគមខ្មែរកម្ពុជាក្រោមប្រចាំខេត្តស្វាយរៀង និងក្រុមគ្រួសាររបស់គាត់ នៅភូមិពោះបូស្ស៊ី ឃុំទួលស្ស៊ី ស្រុកពន្ទ្រា ខេត្តស្វាយរៀង កាលពីថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០០៤ វេលាម៉ោង ១១:០០នាទី ថ្ងៃត្រង់ ។

មន្ត្រីនគរបាលខេត្តស្វាយរៀងចំនួន ០៦នាក់ និងមន្ត្រីនគរបាលវៀតណាមម្នាក់ប្រដាប់ដោយអាវុធ ១២ចូលមកធ្វើការដែកដោះផ្ទះសំបែងរបស់លោក ហ្ស៊ី សុធី ក្រមទាំងថតសួបប្រុកឆ្ម និងកូនៗរបស់គាត់ទៀត ដោយនិយាយថា ពួកគេបានទទួលបញ្ជាពីថ្នាក់លើ ដើម្បីតាមកកាប់ខ្ទង្គលលោក ហ្ស៊ី សុធី ពាក់ព័ន្ធនឹងសៀវភៅប៉ាក្បាលនោះ រួមមាន :

១_សៀវភៅប្រវត្តិវិទ្យាប្រទេសកម្ពុជា ថ្នាក់ទី១២ ដែលបានចោះពុម្ពដោយក្រសួងអប់រំ យុវជន និងកីឡានៃព្រះរាជាណាចក្រកម្ពុជា

២_ប្រវត្តិបត្រស្ត្រីខ្មែរកម្ពុជាក្រោម និង

៣_សៀវភៅប្រជុំរឿងព្រេងខ្មែរកម្ពុជាក្រោម ។

ខ្ញុំសូមផ្តាំលាទាសចំពោះទង្វើ និងសកម្មភាពរបស់មន្ត្រីនគរបាលខេត្តស្វាយរៀង និងមន្ត្រីនគរបាលវៀតណាមដែលបានធ្វើមកលើក្រុមគ្រួសាររបស់លោក ហ្ស៊ី សុធី និងសូមអំពាវនាវឲ្យបញ្ឈប់ជាបន្ទាន់នូវការធ្វើទុក្ខបុកម្នេញ ចុំនមិងចាប់ខ្ទង្គលលោក ហ្ស៊ី សុធី ដើម្បីឲ្យគាត់បានវិលត្រលប់ទៅផ្ទះជុំជាមួយក្រុមគ្រួសារវិញ ។

ភ្នំពេញ, ថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០០៤

យន្ត ៥រ៉ូ
(012 48 11 61)
(011 97 85 83)

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ផ្នែកសារ

សូមជម្រាបជូន
ឯកឧត្តម លោ ណារ៉ាណូ ឧបនាយករដ្ឋមន្ត្រី
ជ្រើមន្ត្រីទ្រទ្រង់ការងារមនុស្ស និងសមាជិកស្ថាប័នអង្គការអន្តរជាតិ

ភាពយោង : លិខិតរបស់ លោ ណារ៉ាណូ ប្រធានរដ្ឋសភា

គោលដៅ : សុំឯកឧត្តមជម្រុញស្ថានកុងស៊ុលនៃ ប្រចាំនៅទីក្រុងប៉ារីស យកចិត្តទុកដាក់ប្រជាពលរដ្ឋខ្មែរនៅទីនោះ ។

ខ្លឹមសារ : _មាត្រា ៣ នៃច្បាប់ស្តីពីសញ្ជាតិ ចានចែងថា ប្រជាពលរដ្ឋខ្មែរដែលកំពុងរស់នៅបរទេសត្រូវមានរដ្ឋតែមួយ ។
_មាត្រា ៣ នៃច្បាប់ស្តីពីសញ្ជាតិ ចានចែងថា ប្រជាពលរដ្ឋខ្មែរដែលកំពុងរស់នៅបរទេសត្រូវមានរដ្ឋតែមួយតាមគ្រប់មាត្រាយោងខាងក្នុង

យោងតាមអត្ថន័ន និងយោងខាងលើ ខ្ញុំសូមជម្រាបជូនឯកឧត្តមមេត្តាជ្រាបว่า ក្នុងរយៈពេលកន្លងមក ប្រជាពលរដ្ឋ និងព្រះសង្ឆប្រចាំដែលកំពុងរស់នៅក្នុងទឹកដីកម្ពុជាក្រោម (រៀតណាមបច្ចុប្បន្ន) ក្យោមអាណាព្យាបាលរបស់រៀតណាម បន្ទាប់ពីបាត់ មានបញ្ហាលំបាកជាច្រើនក្នុងការរស់នៅ ជំនឿណាសនា ភាសាប្រពៃណីទំនៀមទំលាប់ វប្បធម៌ អក្សរសាស្ត្ររបស់ខ្លួន ត្រូវរងការគាបសង្កត់ពីសំណាក់អាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសវៀតណាម ។ ដើម្បីមានតារាងកត់ត្រាលស់ប្រជាពលរដ្ឋ និងព្រះសង្ឆខ្មែរដែលកំពុងរស់នៅទីនោះ ខ្ញុំសូមសុំឯកឧត្តមមេត្តាជួយជម្រុញការងារមួយចំនួន ដូចតទៅក្រោម :

១_បង្កើតស្ថានកុងស៊ុលកិត្តិយសនៃកម្ពុជានៅក្រៅប្រទេស ដូចជាទីក្រុងប្រែកជ្ជស៊ី និងទីក្រុងតូកាយ ព្រមទាំងទីក្រុងតេត្តព្រះត្រពាំង ។ល។ ។

២_ជម្រុញឲ្យស្ថានកុងស៊ុលដែលមានស្រាប់ និងស្ថានកុងស៊ុលបំភ្លឺ ជួយចុះទៅរួមសុខទុក្ខដល់ប្រជា-ពលរដ្ឋ អំពីការរស់នៅរបស់ពួកគាត់ ។

៣_ជួយសំរួលកសាងដែលកើតឡើងចំពោះប្រជាពលរដ្ឋ និងព្រះសង្ឆដែលកំពុងរស់នៅលើទឹកដីខ្លួនតាមរយៈ ឲ្យស្របទៅនឹងមាត្រានានាលើដែនច្បាប់ស្តីពីសញ្ជាតិ និងរដ្ឋធម្មនុញ្ញនៃប្រទេសបារាំង ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមមេត្តាជួយជាវិជ្ជមានការពាមសំណើ គោរពក្តីគន្ទរ ។

សូមឯកឧត្តមទទួលការគោរពដ៏ខ្ពស់ពីខ្ញុំ ។

ភ្នំពេញ, ថ្ងៃទី២៥ ខែកុម្ภៈ ឆ្នាំ២០០៤

លេខ : ...

ទទួលបាន និងចម្លងមក
ឯកឧត្តម ... ...
ដើម្បីសិក្សា ...

ភ្នំពេញ, ថ្ងៃទី ... ...

ប្រធានផ្នែកសារ

ជាទីគោរព
ជ្រាបជូនមក
ឯកឧត្តម ... ...
ដើម្បីសិក្សា ...

ភ្នំពេញ, ...

ប្រធានផ្នែកសារ

ចម្លងជូន :
_ក្រសួងក្រៅប្រទេសកម្ពុជា
_អគ្គលេខាធិការដ្ឋានរដ្ឋសភា-ព្រឹទ្ធសភា
_ទីស្តីការគណៈរដ្ឋមន្ត្រី
_ស្ថានទូតតាមប្រទេសកម្ពុជា
_អង្គការសិទ្ធិមនុស្ស-ជាតិ-អន្តរជាតិ
_សមាជិកជាតិ-អន្តរជាតិ
_ឯកសារ-ការិយាល័យ

ព្រះសង្ឆនិងប្រជាពលរដ្ឋខ្មែរកម្ពុជាក្រោមសុំឲ្យ អ.ស.ប និងអង្គការអន្តរជាតិ លើសកលលោកជួយយកចិត្តទុកដាក់ដល់ស្ត្រីខ្មែរនៅឯកម្ពុជាក្រោមជង

នៅថ្ងៃទី០៨ ធីតា ២០០៤ អង្គការ-សមាគមខ្មែរកម្ពុជាក្រោមបានប្រារព្ធទិវាពិភពលោកនៃនារីលើកទី៨៤ នៅមុនមន្ទីរពេទ្យព្រះសង្ឆរាជធានីភ្នំពេញ ដែលមានចងក្រងជុំជនជាតិយួនសរណាមខ្មែរកម្ពុជាក្រោមចំនួន២៤០នាក់ភាគច្រើនជាស្ត្រីបានចូលរួម ក្រោមអធិបតីភាពដែលមានតំណាង៖ អធិបតីរួមមាន **ព្រះមគ្គុទ្ទេសក៍យសកកិត្តិ ហ្ស៊ីម ស៊ីម** ព្រះប្រធាន KKKBMA **ឯកឧត្តម ហ្ស ម៉ាម** ប្រធាន KKKCCC និងជាសមាជិកវេទិកាជាតិ **ឯកឧត្តម ឃីម ឡាតី** តំណាងរាស្ត្រមណ្ឌលខ្មែរនៅខេត្តកណ្តាល **ឯកឧត្តម ម៉ាត់ សម្ផា** ប្រធាន **KKKC** **លោក ស៊ីន ហ្ស៊ីម** នាយក KKKHRDA លោក ជួន សារ៉ាន តំណាង KKKHRO **លោកស្រី ក្រ ម៉ារ៉ា** នាយិកា KKKWO **លោក ប៊ុក រ៉ែត** តំណាង FKKKA **លោក ហ្ស ស៊ីវ៉ាហ្ក** តំណាង KFP លោក ណុន ចាន់ណា តំណាងអាជ្ញាធរវត្តនានា **ឈ្លាញ ពុធ ណារ៉ា** តំណាងឱ្យស្ត្រីខ្មែរកម្ពុជាក្រោមដែលចូលរួមក្នុងអង្គពិធី និងប្រជាសហគ្មន៍ចំនួន១៦ឃុំ និងមន្ទីរកាលីវ៉ូលីកទី២០៤ ក្រោមកាំរស្មីព្រះអាទិត្យ ដ៏ក្តៅក្រហាយ ។

បន្ទាប់ពីពោរពេញដោយជាតិ និងប្រារព្ធសម្ងាត់ជ្រលង ព្រមទាំងរាប់ផ្ទាល់ជូនដល់អង្គពិធីរួចមក ឯកឧត្តម ហ្ស ម៉ាម ជាតំណាងបើកកម្មវិធីថា ការប្រារព្ធពិធីទាវ៉ាថ្ងៃនេះក្នុងរយៈពេលប៉ុណ្ណាមួយ ដ៏ខ្លីនេះ សំដៅលើកតម្លៃការងារ អង្គការ-សមាគមខ្មែរកម្ពុជាក្រោម **ទីមួយ**. ដើម្បីកសាងវេទិកាទាំងបីដែលបានតម្លៃ ដើម្បីផ្តល់ជូនប្រយោជន៍ឲ្យស្ត្រីនៅលើពិភពលោក **ពីរ**. ដើម្បីជួយសម្រាលទុក្ខដល់ស្ត្រីខ្មែរនៅឯកម្ពុជាក្រោម ពីព្រោះពួកគាត់ពុំដែលស្គាល់ទូវ៉ាវ៉ីដែលហៅว่า សេចក្តីថ្លៃថ្នូររបស់ស្ត្រីម្តងណាឡើយ ដោយសារពួកគាត់ពុំមានសិទ្ធិរៀនសូត្រ ... ...